ស.អ.ក
សហព័ន្ធស្រូវអង្ករកម្ពុជា
CAMBODIA
RICE FEDERATION

មករា - កញ្ញា ២០១៥ | លេខ ០១

# ព្រឹត្តិបត្រព័ត៌មាន

## រួមគ្នាលើកស្ទួយអង្ករកម្ពុជា



www.crf.org.kh / www.facebook.com/cambodiaricefederation

ចេញផ្សាយដោយ

**សហព័ន្ធស្រូវអង្ករកម្ពុជា**

អាស័យដ្ឋាន៖ អគារពាណិជ្ជកម្មសូម៉ា ជាន់ទី ៧
អាគារលេខ ២C ផ្លូវលេខ ១២០ សង្កាត់ ផ្សារថ្មី II
ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
គេហទំព័រ៖ www.crf.org.kh
សារអេឡិចត្រូនិក៖ info@crf.org.kh
ទូរស័ព្ទ៖ +៨៥៥ (0) ២៣ ៥៥៩ ៨៩៩៩
+៨៥៥ (0) ៨៧ ៥៥៩ ៨៩៩

និពន្ធ និងចងក្រងដោយ

ក្រុមការងារលេខាធិការដ្ឋានសហព័ន្ធស្រូវអង្ករកម្ពុជា

ចូលរួមឧបត្ថម្ភដោយ

- NIKOLINE INVESTMENT CO., LTD
- VBH RICE CO., LTD
- ECIC LTD
- ANZ ROYAL
- SOK KEO IMPORT EXPORT CO.,LTD



# មាតិកា

ទំព័រទី

សារ របស់ប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា ៣

សង្ខេបព្រឹត្តិការណ៍សំខាន់ៗ របស់ ស.អ.ក
- មហាសន្និបាតប្រចាំឆ្នាំលើកទី១ របស់ ស.អ.ក ៤
- ទស្សនកិច្ចរបស់ប្រតិភូសហភាពអឺរ៉ុបទទួលបន្ទុកកសិកម្ម និងពាណិជ្ជកម្ម ៥
- កិច្ចប្រជុំពិភាក្សាការងារស្តីពី វិធានប្រមូលពន្ធលើវិស័យស្រូវអង្ករនៅកម្ពុជា ៦
- ប្រធាន ស.អ.ក អញ្ជើញចូលរួមក្នុងសន្និសីទថ្នាក់ជាតិស្តីពីយន្តការអភិវឌ្ឍន៍វិស័យឯកជន ៦
- ប្រធាន ស.អ.ក ចុះជួបជាមួយសហគមន៍កសិករនៅខេត្តសៀមរាប ៧
- ជំនួបពិភាក្សាការងារជាមួយរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ៧
- ជំនួបពិភាក្សាការងារជាមួយរដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល ៨
- ជំនួបពិភាក្សាការងារជាមួយថ្នាក់ដឹកនាំក្រសួងសាធារណៈការនិងដឹកជញ្ជូន ៨
- សហព័ន្ធស្រូវអង្ករកម្ពុជា ចូលរួមចំណែកយ៉ាងសំខាន់នៅក្នុងការធ្វើនំអន្សមយក្សរបស់ខ្មែរ ដែលបានជាប់ក្នុងកំណត់ត្រាពិភពលោក ៩
- កិច្ចប្រជុំពិភាក្សាក្រុមការងារវិស័យឯកជន និងរាជរដ្ឋាភិបាលរបស់វិស័យស្រូវអង្ករកម្ពុជា ៩
- កិច្ចប្រជុំរវាងក្រុមការងារ ស.អ.ក ជាមួយបណ្តាក្រុមហ៊ុន shipping line និងកំពង់ផែទាំងពីរ ១០
- ស.អ.ក ដឹកនាំក្រុមហ៊ុនចំនួន ១០ ចូលរួមបេសកកម្មទីផ្សារនៅក្រុង Guangzhou, Shenzhen និងទីក្រុង Hong Kong ប្រទេសចិន ១០
- ជំនួបពិភាក្សាការងារជាមួយថ្នាក់ដឹកនាំកំពង់ផែស្វយ័តភ្នំពេញ ១១
- ជំនួបពិភាក្សាការងារជាមួយថ្នាក់ដឹកនាំកំពង់ផែស្វយ័តក្រុងព្រះសីហនុ ១១
- ប្រធាន ស.អ.ក បានទៅបំពេញទស្សនកិច្ចជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅសាធារណរដ្ឋប្រជាមានិតចិន ១១
- កិច្ចប្រជុំជាមួយអាជ្ញាធរអគ្គិសនីកម្ពុជា ១២
- ប្រធាន សហព័ន្ធស្រូវអង្ករកម្ពុជា បានចូលរួមក្នុងកិច្ចប្រជុំពិគ្រោះយោបល់ស្តីពីការអភិវឌ្ឍអាទិភាពរបស់កម្ពុជា ១២
- ពិធីចុះហត្ថលេខា លើអនុស្សរណៈនៃការយោគយល់គ្នារវាងក្រសួងពាណិជ្ជកម្ម និងសហព័ន្ធស្រូវអង្ករកម្ពុជា ១៣
- ជំនួបពិភាក្សាការងារជាមួយរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម ១៤
- ជំនួបពិភាក្សាការងារជាមួយថ្នាក់ដឹកនាំអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ១៤
- សហព័ន្ធស្រូវអង្ករកម្ពុជា ចូលរួមនៅក្នុងវេទិកាធុរកិច្ចកម្ពុជា-បេឡារុស ១៥
- សហព័ន្ធស្រូវអង្ករកម្ពុជា ចូលរួមនៅក្នុងពិធីប្រកាសផ្សព្វផ្សាយ និងដាក់ឲ្យអនុវត្ត គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ ២០១៥-២០២៥ ១៨
- ទស្សនកិច្ចសមាគមអភិវឌ្ឍន៍កសិផលស្រុកបារាយណ៍ ១៨
- កិច្ចប្រជុំគណៈកម្មាធិការប្រតិបត្តិទាំង ៥ របស់ ស.អ.ក ១៨
- ស.អ.ក ស្វែងរកកិច្ចសហការលំហូរទិន្នន័យព័ត៌មានពីអគ្គនាយកដ្ឋានកសិកម្ម នៃក្រសួងកសិកម្ម ១៩

ព័ត៌មានអំពី គណៈកម្មាធិការប្រតិបត្តិទាំង ៥ របស់ ស.អ.ក ២០
ស្ថិតិនៃរបាយការណ៍នាំចេញអង្ករកម្ពុជា ២៥
ព្រឹត្តិការណ៍សំខាន់ៗ នាពេលខាងមុខ ២៦
អំពីសមាជិក ស.អ.ក ២៨

# សារ របស់ប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា

*ឯកឧត្តម **សុខ ពុទ្ធិវុធ** ប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា*

ជាបឋម ខ្ញុំសូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះសមាជិកទាំងអស់ដែលបានគាំទ្ររហូតមក ដល់សហព័ន្ធស្រូវអង្ករកម្ពុជា។ ខ្ញុំមានសេចក្តីរីករាយជាពន់ពេកដែលសហព័ន្ធស្រូវអង្ករកម្ពុជារបស់យើងនៅតែបង្ហាញនូវសាមគ្គីភាព ចំណាប់អារម្មណ៍ និងការខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្លាចូលរួមក្នុងការដោះស្រាយបញ្ហាប្រឈមក្នុងវិស័យស្រូវអង្ករ។ វាពិតជាមានសារៈសំខាន់ណាស់ ដែលយើងទាំងអស់គ្នាបន្តបង្ហាញនូវសាមគ្គីភាព និងបំណងនៃការជួយដល់សហព័ន្ធ ក្នុងការបន្តធ្វើការងារ ប្រមូលផ្តុំភាគីពាក់ព័ន្ធទាំងអស់ដូចជារាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងវិស័យឯកជន ក្នុងការធ្វើការរួមគ្នាដើម្បីអភិវឌ្ឍសង្វាក់ផលិតកម្មស្រូវអង្ករកម្ពុជា។

រយៈពេលប៉ុន្មានឆ្នាំនេះ ទីផ្សារទំនិញពិភពលោក ដែលរួមមានអង្ករផងដែរ មានការធ្លាក់ចុះ ហើយសម្រាប់ការប្រមើលមើលទៅអនាគត យើងនៅមានភាពស្រពិចស្រពិលនៅឡើយ ។ ប៉ុន្តែយើងនៅអាចមើលឃើញថា ផ្នែកតម្រូវការ នៅតែបន្តកើនឡើង ហើយក៏ជាការមួយចាំបាច់ណាស់ដែលប្រទេសកម្ពុជាត្រូវត្រៀមខ្លួនអោយបានស្រេច និងកំណត់នូវជំហាននៃវិស័យស្រូវអង្កររបស់យើង ដើម្បីទាញយកអត្ថប្រយោជន៍នៃការរីកចម្រើននាថ្ងៃអនាគតដែលកើតចេញតម្រូវការនូវសន្តិសុខស្បៀងសំរាប់ផ្គត់ផ្គង់ដល់ប្រជាជនដែលចេះតែកើនឡើង ហើយដែលត្រូវគេរំពឹងថានឹងមានចំនួនជាង ៩ពាន់លាននាក់ ដល់ឆ្នាំ២០៥០។ ជាមួយគ្នានេះ យើងក៏ត្រូវការផងដែរ នូវសង្វាក់ផ្គត់ផ្គង់មួយដែលល្អ មានតម្លាភាព និងអាចត្រួតពិនិត្យតាមដាន ដើម្បីធានាបាននូវគុណភាពល្អបំផុតសម្រាប់ទីផ្សារ និងអ្នកប្រើប្រាស់។ យើងត្រូវបន្តកែលំអអោយប្រសើរឡើងនូវដំណើរការនៃការធានានូវគុណភាពរបស់យើង ដើម្បីឆ្លើយតបនឹងស្តង់ដាររបស់ទីផ្សារ ទើបយើងអាចពង្រីកការជំរុញលើកស្ទួយអង្ករល្អបំផុតរបស់ពិភពលោករបស់យើង។

ក្រុមនៃសហព័ន្ធស្រូវអង្ករបានខិតខំប្រឹងប្រែងរហូតមកជាមួយភាគីពាក់ព័ន្ធទាំងអស់នៅគ្រប់ជាន់ថ្នាក់ដើម្បីចូលរួមទាំងអស់គ្នាចេញពីគោលនយោបាយនៃការជួយកសិករនៅតាមភូមិនានា។ មានការងារជាច្រើនដែលបានធ្វើរួចហើយ នាពេលកន្លងមក ដើម្បីស្វែងយល់ពីឫសគល់ ដែលនាំយើងអោយស្ថិតក្នុងស្ថានភាពសព្វថ្ងៃ។ សហព័ន្ធស្រូវអង្ករកម្ពុជា និងភាគីពាក់ព័ន្ធនឹងធ្វើការជាមួយគ្នាក្នុងការដាក់ចេញនូវកម្មវិធីសំខាន់ៗ និងការរៀបចំផែនការរហូតដល់បំណាច់ឆ្នាំនេះ ដើម្បីស្នើសុំទៅរាជរដ្ឋាភិបាលនិងភាគីពាក់ព័ន្ធទាំងអស់ នូវមធ្យោបាយនានា ក្នុងការអភិវឌ្ឍនិងធ្វើទំនើបកម្មសង្វាក់ផលិតកម្មស្រូវអង្ករកម្ពុជា។ សហព័ន្ធស្រូវអង្ករកម្ពុជា បានកំណត់អត្តសញ្ញាណ និងយកជាអាទិភាពនូវរបៀបវារៈចំនួន **៣** នៅក្នុងឆ្នាំនេះ និងឆ្នាំក្រោយ ដែលរួមមាន៖

១- ដំណោះស្រាយក្រោយការប្រមូលផល (ដំណោះស្រាយឥណទាន និងការបញ្ចូលបច្ចេកវិទ្យា)

២- ស្រូវពូជ

៣- ពង្រីកទីផ្សារ

នៅក្នុងប៉ុន្មានខែនេះ ក្រុមការងារនៃសហព័ន្ធស្រូវអង្កររបស់យើង បានខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្នុងការផ្សារភ្ជាប់និងជួបជាមួយភាគីពាក់ព័ន្ធជាច្រើន។ យើងមានទំនាក់ទំនងធ្វើការងារយ៉ាងល្អប្រសើរជាមួយក្រសួងពាណិជ្ជកម្ម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ខ្ញុំក៏មានមោទនភាពផងដែរ ក្នុងការជំរាបជូនថា យើងបានប្រឹងប្រែង រហូតទទួលបានការគាំទ្រពីសហគមន៍អន្តរជាតិដ៏ធំមួយ នោះគឺ វេទិកាសេដ្ឋកិច្ចពិភពលោក (World Economic Forum) ដែលនឹងគាំទ្រយើងនៅច្រើនកំរិត ចាប់តាំងពី គោលនយោបាយ ការស្រាវជ្រាវ បច្ចេកទេស រហូតដល់ការវិនិយោគ។ យើងក៏កំពុងធ្វើការជាមួយដៃគូអភិវឌ្ឍន៍ដទៃទៀតក្នុងការចាក់បញ្ចូលនូវធនធានរបស់យើងជាមួយគ្នា និងអភិវឌ្ឍបន្ថែមទៀតលើកម្មវិធីដែលមានស្រាប់។ ហើយយើងបន្តធ្វើការយ៉ាងជិតស្និទ្ធជាមួយក្រសួងពាក់ព័ន្ធទាំងអស់។

នៅឆ្នាំនេះ យើងសង្ឃឹមថានឹងពង្រីកបន្ថែមទៀតនូវចំណងទាក់ទងរបស់ប្រទេសយើង ដើម្បីទទួលយកនូវគម្រោងរវាងរដ្ឋនិងរដ្ឋ ដើម្បីពង្រីកការនាំចេញ។ យើងក៏សង្ឃឹមផងដែរ ក្នុងការទទួលនូវកូតាពីប្រទេសចិន និងប្រទេសអាស៊ានដទៃទៀត។

សហព័ន្ធស្រូវអង្ករកម្ពុជា នឹងចូលរួមក្នុងក្រុមការងារទី៩ នៃវេទិការវាងរដ្ឋនិងឯកជន ដែលនេះមានសារៈសំខាន់ដើម្បីឲ្យសហព័ន្ធ អាចធ្វើការក្នុងកំរិតគោលនយោបាយជាមួយរាជរដ្ឋាភិបាល និងជាផ្នែកមួយនៃក្រុមដែលនឹងជួយស្វែងរកដំណោះស្រាយសម្រាប់វិស័យស្រូវអង្ករ។ ខ្ញុំជឿជាក់ថា គឺជាគំនិតមួយដ៏ល្អដែលយើងបង្ហាញនូវសាមគ្គីភាពគ្នាក្នុងវិស័យស្រូវអង្ករដោយរក្សានូវរចនាសម្ព័ន្ធដឹកនាំមួយ ដូចគ្នានឹងសហព័ន្ធស្រូវអង្ករកម្ពុជា។

ខ្ញុំបានជួបនឹងមនុស្សនិងអង្គការជាច្រើន ហើយយើងទាំងអស់គ្នាគិតថា កសិកម្ម គឺមានអនាគតភ្លឺថ្លា ប៉ុន្តែចាំបាច់ត្រូវយើងធ្វើការជាមួយគ្នាក្នុងការកសាងនូវទំនុកចិត្តមួយឲ្យកាន់តែខ្លាំង និងទាញយកនូវអត្ថប្រយោជន៍ពីបច្ចេកទេស បច្ចេកវិទ្យា និងការវិនិយោគថ្មីៗ។ យើងត្រូវតែធ្វើទំនើបកម្មនៃការគិតរបស់យើងអំពីអ្វីដែលជា កសិករក្នុងសតវត្សទី ២១។

រាជធានីភ្នំពេញ ថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៥
ប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា

**សុខ ពុទ្ធិវុធ**



# មហាសន្និបាតប្រចាំឆ្នាំលើកទី ១ របស់ ស.អ.ក

មហាសន្និបាតប្រចាំឆ្នាំលើកទី ១ របស់សហព័ន្ធស្រូវអង្ករកម្ពុជា (ស.អ.ក) បាន ប្រារព្ធ ធ្វើ ប្រកបដោយជោគជ័យ នៅថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០១៥ នៅសណ្ឋាគារ ភ្នំពេញ ដោយមានការអញ្ជើញចូលរួមពី អ្នកធ្វើការ ពាក់ព័ន្ធវិស័យស្រូវអង្ករជាង ២៦០ នាក់ ដោយក្នុងនោះរួមមាន ម្ចាស់ម៉ាស៊ីនកិនស្រូវ អ្នកនាំចេញស្រូវអង្ករ សហគមន៍កសិករ ក្រសួងដែលពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍ផ្សេងទៀត។




កិច្ចប្រជុំត្រូវ បានប្រារព្ធឡើងក្រោមអធិបតីរបស់ ឯកឧត្តម ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម **ស៊ុន ចាន់ថុល**។ គោលបំណងនៃការប្រជុំមាន បីសំខាន់ៗដែលរួមមាន៖

(១) ការបូកសរុប និងរាយការណ៍សមិទ្ធផលរបស់ ស.អ.ក

(២) ការបង្ហាញពីផែនការយុទ្ធសាស្រ្ត របស់ ស.អ.ក ក្នុងការលើកស្ទួយការកើនឡើងនូវវិស័យស្រូវអង្ករកម្ពុជា

(៣) ការជួបជាមួយអ្នកដែលធ្វើការពាក់ព័ន្ធផ្នែកស្រូវអង្ករ ជាពិសេសសមាជិករបស់ ស. អ. ក ដើម្បីស្តាប់ និងពិភាក្សារកដំណោះស្រាយបញ្ហាដែលជួបប្រទះ។



*ប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា លោក **សុខ ពុទ្ធីវុធ***

ជាកិច្ចចាប់ផ្តើមកិច្ចប្រជុំ ប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា (ស.អ.ក) លោក **សុខ ពុទ្ធីវុធ** បានមានប្រសាសន៍បើកកិច្ចប្រជុំ ដោយស្វាគមន៍ចំពោះសមាជិកដែលបានចូលរួមទាំងអស់ និងធ្វើបទបង្ហាញពីផែនការសកម្មភាពរបស់ ស.អ.ក សម្រាប់ឆ្នាំ ២០១៥ មានឈ្មោះថា "ផែនការមាសស" ដែលធ្វើឡើងក្នុងគោលបំណងលើកស្ទួយវិស័យ ស្រូវអង្ករនៅក្នុងប្រទេសកម្ពុជាទាំងមូល។ លោក **សុខ ពុទ្ធីវុធ** បានឲ្យដឹងថា ផែនការនេះនឹងផ្តោតសំខាន់ទៅលើដំណោះស្រាយសមស្របមួយចំនួន ក្នុងការលើកស្ទួយវិស័យកសិកម្ម ដែលរួមមាន លទ្ធភាពនៃការទទួលបានហិរញ្ញវត្ថុ ការផ្សព្វផ្សាយផ្នែកទីផ្សារ និងយីហោ ការពង្រីកផលិតផលគ្រាប់ពូជស្រូវដែលមានគុណភាព និងការកាត់បន្ថយការចំណាយផ្សេងៗ ។ល។



ការធ្វើបទបង្ហាញផ្សេងៗទៀតក៏ត្រូវបានធ្វើឡើង ក្នុងអំឡុងកិច្ចប្រជុំប្រចាំឆ្នាំលើកទី១ របស់ ស.អ.ក ផងដែរ រួមមានការធ្វើបទបង្ហាញអំពី៖ (១) សមិទ្ធផលសំខាន់ៗរបស់ ស.អ.ក ក្នុងឆ្នាំកន្លងមក (២) បទបញ្ជាផ្ទៃក្នុងរបស់ ស.អ.ក (៣) ក្រមសីលធម៌ និងវិន័យរបស់ ស.អ.ក និង (៤) រចនាសម្ព័ន្ធថ្មីរបស់ ស.អ.ក។

បន្ថែមពីនេះទៀត កិច្ចពិភាក្សាត្រូវបានបើកចំហរ និងផ្តល់ជូនអ្នកចូលរួមទាំងអស់ក្នុងការចែករំលែកគំនិត និងមតិយោបល់របស់ពួកគាត់។ អ្នកចូលរួមទាំងអស់ បានផ្តល់នូវយោបល់រួមមួយ ដែលថាអ្នកធ្វើការពាក់ព័ន្ធនឹងវិស័យស្រូវអង្ករទាំងអស់ត្រូវតែធ្វើការរួមគ្នាជាមួយ ស.អ.ក ដើម្បីដោះស្រាយបញ្ហាដែលប្រឈម ។ អ្នកចូលរួមទាំងអស់ក៏បានលើកឡើងពីការព្រួយបារម្ភ និងធ្វើការស្នើសុំឲ្យមានភាពប្រសើរឡើង ផ្នែកគុណភាពផលិតផលស្រូវអង្ករ ការផ្សព្វផ្សាយទីផ្សារនាំចេញ និងការកាត់បន្ថយការចំណាយភស្តុភារផ្សេងៗ (logistic cost)៕



# ទស្សនកិច្ចរបស់ប្រតិភូសហភាពអឺរ៉ុបទទួលបន្ទុកកសិកម្ម និងពាណិជ្ជកម្ម



កិច្ចប្រជុំធ្វើឡើងនៅ ការិយាល័យ ស.អ.ក

អគ្គនាយកសហភាពអឺរ៉ុបផ្នែកកសិកម្ម និងអភិវឌ្ឍន៍ជនបទ និងអគ្គនាយកផ្នែកពាណិជ្ជកម្ម បានបំពេញបេសកម្មរួមគ្នាមួយទស្សនកិច្ចនៅកម្ពុជាចំនួនបីថ្ងៃចាប់ពីថ្ងៃទី ១៨ ដល់ថ្ងៃទី២០ខែមីនា ឆ្នាំ២០១៥ ដើម្បីប្រឹក្សាយោបល់ជាមួយក្រសួងពាណិជ្ជកម្ម និងសហព័ន្ធស្រូវអង្ករកម្ពុជា (CRF) ស្តីពីការនាំចេញអង្ករទៅកាន់សហភាពអឺរ៉ុប។

ក្នុងស្មារតីនៃភាពជាដៃគូជិតស្និទ្ធរវាងវិស័យសាធារណៈ និងឯកជនជាមួយក្រសួងពាណិជ្ជកម្ម សហព័ន្ធស្រូវអង្ករកម្ពុជា (CRF) បានសហការពេញលេញ និងពិភាក្សាដោយស្មោះត្រង់ជាមួយគណៈកម្មការអឺរ៉ុប ព្រមទាំងបានចែករំលែកជាមួយមន្ត្រីអឺរ៉ុបនូវផែនការសកម្មភាពយុទ្ធសាស្ត្រនៃឧស្សាហកម្មស្រូវអង្ករ ដែលនឹងត្រូវអនុវត្តក្នុងពេលខាងមុខនេះ និងកិច្ចខិតខំប្រឹងប្រែងដើម្បីលើកកំពស់តម្លៃបន្ថែម ឧស្សាហកម្មស្រូវអង្កររួមចំណែកផ្តល់ប្រយោជន៍ដល់ការលើកកំពស់ជីវភាពរស់នៅរបស់កសិករកម្ពុជា ដែលជាស្នូលនៃគំនិតផ្តួចផ្តើម « **អ្វីក៏ដោយលើកលែងតែអាវុធ** (EBA) » របស់សហភាពអឺរ៉ុប។

សហព័ន្ធស្រូវអង្ករកម្ពុជា (CRF) ដឹងថា ចំណែកទីផ្សារអង្ករពិតប្រាកដដែលកម្ពុជាទទួលបាន ២២% ក្នុងទីផ្សារអង្ករនៅសភាពអឺរ៉ុប បានបង្កើតឲ្យមានភាពមិនស្រួលចិត្តពីសំណាក់អ្នកផលិតនៅតំបន់អឺរ៉ុប។

ក្នុងនាមជាអ្នកនាំចេញថ្មីថ្មោងក្នុងទីផ្សារអង្ករពិភពលោក និងបានជាប់ចំណាត់ថ្នាក់ជាអង្ករល្អបំផុតនៅក្នុងពិភពលោក « World Best Rice » បីឆ្នាំជាប់ៗគ្នា, ឧស្សាហកម្មស្រូវអង្ករកម្ពុជា កំពុងផ្លាស់ប្តូរទៅរកគុណភាពអង្ករក្រអូបកាន់តែច្រើន ជាងបរិមាណនាំចេញច្រើននៃអង្ករសធម្មតា (LGWR)។ ស្ថិតិបានបញ្ជាក់ថា កាលពី ៦ឆ្នាំមុន ការនាំចេញអង្ករកម្ពុជា ផ្តោតសំខាន់ទៅ (LGWR) ខណៈដែលអង្ករផ្ការម្លិះ និងអង្ករក្រអូបផ្សេងៗទៀតមានភាគរយតិចតួចប៉ុណ្ណោះ។

មកដល់ឆ្នាំ ២០១៤ ទិន្នន័យនាំចេញបានបង្ហាញថា អង្ករផ្ការម្លិះ និងអង្ករក្រអូប បានហក់ឡើងខ្ពស់រហូតដល់ជិត ៦០% នៃការនាំចេញសរុប។

ការចុះបញ្ជី សំគាល់ភូមិសាស្ត្រ (GI) កំពុងត្រូវបានពិចារណា ចំពោះអង្ករផ្ការម្លិះកម្ពុជា ដើម្បីលើកកម្ពស់តម្លៃ និងមានតួនាទីច្បាស់លាស់នៅទីផ្សារ។ ឧស្សាហកម្មអង្ករកម្ពុជា កំពុងផ្លាស់ប្តូរពីការផ្តោតលើបរិមាណ មកកាន់ផ្តោតលើគុណភាព។ ទិន្នន័យនាំចេញអង្ករកម្ពុជារយៈពេល ពីរខែដំបូងឆ្នាំ ២០១៥ បានបង្ហាញឲ្យឃើញពីការធ្លាក់ចុះនៃចំណែកទីផ្សារអឺរ៉ុប រហូតដល់ទៅ ៣០% ក្នុងរយៈពេលដូចគ្នាកាលពីឆ្នាំ ២០១៤ ខណៈដែលទីផ្សារអាស៊ីបានកើនឡើង ៣ដង ដែលជាផ្នែកមួយនៃដំណើរការទីផ្សារក្នុងពេលថ្មីៗនេះ។

ប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា លោក **សុខ ពុទ្ធិវុធ** បានអធិប្បាយថា « ទោះបីយើងឃើញនូវកំណើនដ៏ឆាប់រហ័សនៅទីផ្សារអឺរ៉ុបក្នុងរយៈពេល ៣ឆ្នាំ យើងជឿថា តួលេខនាំចេញឆ្នាំ ២០១៤ បានបង្ហាញរួចរាល់នូវកម្រិតនាំចេញជាអតិបរមា ហើយយើងនៅតែចង់បានការរីកចម្រើនកាន់តែខ្លាំងនៅទីផ្សារអឺរ៉ុបបន្ថែមទៀត។ យើងនៅតែជាអ្នកផលិតតូចមួយនៅក្នុងពិភពលោក ប្រៀបធៀបជាមួយអ្នកនាំចេញផ្សេងទៀតនៅក្នុងអាស៊ី។ យើងស្ថិតនៅចំកណ្តាលនៃទីផ្សារនាំចេញជាមួយការផ្លាស់ប្តូរយុទ្ធសាស្ត្រ ផ្តោតសំខាន់ផលិតកម្ម និងនាំចេញអង្ករក្រអូបឲ្យបានកាន់តែច្រើន»៕



រូបថតអនុស្សាវរីយ៍ (នៅការិយាល័យ ស.អ.ក ភ្នំពេញ)

## កិច្ចប្រជុំពិភាក្សាការងារស្តីពី វិធានប្រមូលពន្ធលើវិស័យស្រូវអង្ករនៅកម្ពុជា

នៅព្រឹកថ្ងៃទី ២៥ ខែមីនា ឆ្នាំ ២០១៥ នៅអគ្គនាយកដ្ឋានពន្ធដារ មានកិច្ចប្រជុំមួយរវាង ក្រុមការងារ ស.អ.ក ជាមួយថ្នាក់ដឹកនាំអគ្គនាយកដ្ឋានពន្ធដារ ដើម្បីពិភាក្សារការងារស្តីពី វិធានប្រមូលពន្ធលើវិស័យស្រូវអង្ករនៅកម្ពុជា។ ក្រុមការងារ ស.អ.ក ដែលដឹកនាំដោយប្រធាន ស.អ.ក លោក **សុខ ពុទ្ធិវុធ** និងលោក ឧកញ៉ា **គីម សាវុធ** អនុប្រធានស.អ.ក និងជាប្រធានគណៈកម្មាធិការការងារថ្លៃដើម រួមទាំងសមាជិក សរុប ៣៧ នាក់ និងថ្នាក់ដឹកនាំអគ្គនាយកដ្ឋានពន្ធដារ មានចំនួនសរុប ១០ នាក់ ដឹកនាំដោយ ឯកឧត្តម **គង់ វិបុល** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ។

នៅក្នុងកិច្ចប្រជុំ លោក **សុខ ពុទ្ធិវុធ** បានជំរាបប្រាប់ដល់ថ្នាក់ដឹកនាំអគ្គនាយកដ្ឋានពន្ធដារអំពីបញ្ហាប្រឈមសំខាន់ៗចំនួន ៤ ចំណុច ដែលសមាជិក ជារោងម៉ាស៊ីនកិនស្រូវ និងអ្នកនាំចេញបាន និងកំពុងជួយប្រទះរួមមាន៖ (១) ពន្ធ ១% នៃប្រាក់ចំណេញ (២) ពន្ធ ២% នៃ ស្តុក (៣) VAT នៃ Trucking/Logistic (៤) ការទំនាក់ទំនង និងលំហូរព័ត៌មានពីអគ្គនាយកដ្ឋានពន្ធដារ។





ជាការឆ្លើយតប ថ្នាក់ដឹកនាំអគ្គនាយកដ្ឋានពន្ធដារបានធ្វើបទបង្ហាញខ្លីមួយស្តីពី វិធានប្រមូលពន្ធលើវិស័យស្រូវអង្ករ និងអត្ថប្រយោជន៍ដែលរោងម៉ាស៊ីនកិនស្រូវ និងអ្នកនាំចេញនឹងទទួលបានពេលចុះបញ្ជីជារបបពិត។ បន្ថែមពីនេះ ឯកឧត្តម **គង់ វិបុល** បានស្នើនិងលើកទឹកចិត្តដល់សមាជិក ស.អ.ក ទាំងអស់ ធ្វើការចុះបញ្ជីជារបបពិតវិញ ដោយឯកឧត្តមបានបញ្ជាក់ថា នឹងទទួលបានអត្ថប្រយោជន៍និងការលើកលែងពន្ធជាច្រើន។ឯកឧត្តមក៏បានសន្យាថា នឹងផ្តល់ជូនការសម្របសម្រួលមួយជាពិសេស សម្រាប់ការចុះបញ្ជីជារបបពិត ជូនដល់សមាជិករបស់ស.អ.ក នៅពេលខាងមុខនេះផងដែរ។

ជាលទ្ធផល កិច្ចប្រជុំសម្រេចបានលទ្ធផលជាផ្លែផ្កាជាច្រើន ដោយភាគីទាំងពីរបានយល់គ្នាកាន់តែច្បាស់ ហើយភាគីអគ្គនាយកដ្ឋានពន្ធដារបានសន្យា ពង្រឹងកិច្ចសហប្រតិបត្តិការបន្ថែមទៀតជាមួយ ស.អ.ក។ ភាគី ស.អ.ក នឹងធ្វើការផ្សព្វផ្សាយទៅដល់សមាជិក ដើម្បីលើកទឹកចិត្តសមាជិកឲ្យចុះបញ្ជីជារបបពិត៕

## ប្រធាន ស.អ.ក អញ្ជើញចូលរួមក្នុងសន្និសីទថ្នាក់ជាតិស្តីពីយន្តការអភិវឌ្ឍន៍វិស័យឯកជន

នៅថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥ នៅសណ្ឋាគារកាំបូឌីយ៉ាណា លោក **សុខ ពុទ្ធិវុធ** បានអញ្ជើញចូលរួមក្នុងសន្និសីទថ្នាក់ជាតិ ស្តីពី យន្តការអភិវឌ្ឍន៍វិស័យឯកជនក្រោមប្រធានបទ៖ "សហថាមពល កំណើន និងសហគមន៍សេដ្ឋកិច្ចអាស៊ាន" ។ សន្និសីទនេះ រៀបចំឡើងដោយសភាពាណិជ្ជកម្មកម្ពុជាសហការជាមួយក្រសួងពាណិជ្ជកម្ម។



*សកម្មភាពសន្និសីទ នៅសណ្ឋាគារកាំបូឌីយ៉ាណា*

សន្និសីទនេះមានអ្នកចូលរួមប្រមាណ ១៦០ នាក់ ជាតំណាងអញ្ជើញមកពីវិស័យឯកជន រដ្ឋាភិបាល ផ្នែកសិក្សាធិការ ស្ថាប័នដៃគូអភិវឌ្ឍន៍។ សន្និសីទនេះ រៀបចំឡើងក្នុងគោលបំណងប្រមូលផ្តុំវិស័យឯកជនទាំងឡាយ ដែលពាក់ព័ន្ធនឹងគំនិតផ្តួចផ្តើមអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាលកម្ពុជា ដៃគូអភិវឌ្ឍន៍ និងដៃគូផ្សេងៗទៀត ដើម្បីបង្កើតបរិយាកាស កាន់តែប្រសើរ ឡើងក្នុង ការ ធ្វើពាណិជ្ជកម្មនៅកម្ពុជា។ នៅអំឡុងពេលសន្និសីទ លោក **សុខ ពុទ្ធិវុធ** បានធ្វើបទអន្តរាគមន៍និងបង្ហាញអំពី សុខដុមនីយកម្មនៃការសម្រេចចិត្តជាយុទ្ធសាស្ត្ររបស់វិស័យឯកជនជាមួយ នឹងគោលនយោបាយយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលកម្ពុជា (កំណើសិក្សាលើវិស័យស្រូវអង្ករ) ដោយលោកបានលើកឡើងអំពីឯកសារគោលនយោបាយមួយចំនួនស្តីពីការជម្រុញផលិតកម្មស្រូវ និងការនាំចេញអង្ករ បច្ចុប្បន្នភាពនៃការនាំចេញ និងការងារជាអទិភាពមួយចំនួនដែលបាន និងកំពុងអនុវត្តន៍ដោយ ស.អ.ក។ លើសពីនេះ លោក **សុខ ពុទ្ធិវុធ** ក៏បានចូលរួមជាវាគ្មិននៅ ក្នុងកិច្ចពិភាក្សាពេញអង្គ ដោយមានការសួរឆ្លើយផងដែរ៕



*សកម្មភាពសន្និសីទ នៅសណ្ឋាគារកាំបូឌីយ៉ាណា*

## ប្រធាន ស.អ.ក ចុះជួបជាមួយសហគមន៍កសិករនៅខេត្តសៀមរាប



នៅថ្ងៃទី ២៦ ខែមីនា ឆ្នាំ ២០១៥ ប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា (ស.អ.ក) លោក **សុខ ពុទ្ធិវុធ** និងក្រុមការងារបានចុះជួបជាមួយសហគមន៍កសិករប្រមាណជិត ១០០នាក់ នៅឃុំដូនពេង ក្នុងស្រុកអង្គរជុំ ខេត្តសៀមរាប ដើម្បីស្វែងយល់បញ្ហាប្រឈមដែល សហគមន៍កសិករកំពុងជួបប្រទះ និងស្វែងរកវិធីដោះស្រាយជួយដល់សមាគមកសិករ។



*សកម្មភាពជួបជុំ សហគមន៍កសិករ នៅខេត្តសៀមរាប*

គោលគំនិតនៃការដោះស្រាយគឺ ការចងក្រងកសិករក្នុងការសហការគ្នា ធ្វើរួមគ្នា ដើម្បីបន្ថយចំណាយជ្រើសរើសពូជសុទ្ធល្អដែលឆ្លើយតបទីផ្សារ និងបង្កើនប្រាក់ចំណេញក្នុងការធ្វើស្រែរបស់កសិករ៕

## ជំនួបពិភាក្សាការងារជាមួយរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

នៅថ្ងៃទី ២៤ ខែមេសា ឆ្នាំ ២០១៥៖ ថ្នាក់ដឹកនាំសហព័ន្ធស្រូវអង្ករកម្ពុជា ដឹកនាំដោយប្រធាន ស.អ.ក លោក **សុខ ពុទ្ធិវុធ** លោកឧកញ៉ា **គឹម សាវុធ** និង លោកឧកញ៉ា **ហ៊ុន ឡាក់** អនុប្រធាន ស.អ.ក និងសមាជិកគណៈកម្មាធិការប្រតិបត្តិផលិតភាពផលិតកម្ម និងការកែច្នៃ បានជួបសម្តែងការគួរសមជាមួយឯកឧត្តម បណ្ឌិត **អ៊ុក រ៉ាប៊ុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខប្រមាញ់ និង នេសាទ និងមន្ត្រីជាន់ខ្ពស់របស់ក្រសួងផ្នែកជំនាញបច្ចេកទេសជាច្រើនទៀត។

គោលបំណងនៃជំនួបនេះ គឺស្នើសុំកិច្ចសហការការងាររវាងសហព័ន្ធស្រូវអង្ករកម្ពុជា និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ លើការងារបច្ចេកទេសដាំដុះស្រូវ និងពង្រីកផលិតកម្មពូជស្រូវ និងចែករំលែកព័ត៌មានជាដើម។ល។



*រូបភាពនៅទីស្តីការក្រសួងកសិកម្ម*

លោក **សុខ ពុទ្ធិវុធ** បានជម្រាបជូនរដ្ឋមន្ត្រីអំពីដំណើរការវិវត្តន៍របស់សហព័ន្ធស្រូវអង្ករកម្ពុជា ក្នុងការជួយលើកស្ទួយដល់ការនាំអង្ករចេញ និងគាំទ្រដល់សមាជិក ជាពិសេសកសិករខ្មែរ។ លោកប្រធានសហព័ន្ធក៏បានជម្រាបប្រាប់អំពីផលលំបាកមួយចំនួនទាក់ទងនឹង បញ្ហាថ្លៃដើមខ្ពស់នៅក្នុងវិស័យស្រូវអង្ករ និងបញ្ហាបរិមាណ និងគុណភាពស្រូវអង្កររបស់យើងនៅមានកម្រិតដែលជាហេតុធ្វើឲ្យជួបការលំបាកក្នុងការប្រកួតប្រជែងជាមួយប្រទេសជិតខាង។

ឆ្លើយតបទៅនឹងសំណើ របស់ ស.អ.ក ឯកឧត្តមរដ្ឋមន្ត្រី បានមានប្រសាសន៍កោតសរសើរអំពីការងារ និងដំណើរការវិវត្តន៍របស់ ស.អ.ក និងបានគាំទ្រចំពោះសំណើកិច្ចសហការជាមួយក្រសួង ជាពិសេសទាក់ទ ង នឹងបញ្ហាបច្ចេកទេស ដូចជាការបង្កើននូវបរិមាណទិន្នផលស្រូវ និងពង្រីកនូវផលិតភាពពូជស្រូវជាដើម។



ដោយឡែក ចំពោះបញ្ហាទាក់ទងនឹងបញ្ហាគោលនយោបាយ ឯកឧត្តមបានផ្តល់ជាអនុសាសន៍ថា ទុកពិភាក្សាតាមរយៈក្រុមការងារទី ៩ ផ្នែកស្រូវ អង្ករ របស់ផ្នែកឯកជននៃវេទិការាជរដ្ឋាភិបាលផ្នែកឯកជន។

ជាចុងក្រោយ ភាគីសហព័ន្ធស្រូវអង្ករកម្ពុជា បានអរគុណចំពោះថ្នាក់ដឹកនាំក្រសួង ដែលបានគាំទ្រ និងបន្តកិច្ចសហការជាមួយសហព័ន្ធស្រូវអង្ករកម្ពុជាទៅថ្ងៃខាងមុខ៕

## ជំនួបពិភាក្សាការងារជាមួយរដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល

ថ្នាក់ដឹកនាំសហព័ន្ធស្រូវអង្ករកម្ពុជា ដឹកនាំដោយប្រធាន ស.អ.ក លោក **សុខ ពុទ្ធិវុធ** និងលោកឧកញ៉ា **គឹម សាវុធ** អនុប្រធាន ស. អ. ក និងជាប្រធានគណៈកម្មាធិការប្រតិបត្តិកែទម្រង់ថ្លៃដើមបានជួបសំដែងការគួរសមជាមួយឯកឧត្តម **ស៊ុយ សែម** រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល និងមន្ត្រីជាន់ខ្ពស់ របស់ក្រសួង និងអគ្គិសនីកម្ពុជាផងដែរ។
គោលបំណងនៃជំនួបនេះ គឺស្នើសុំឲ្យក្រសួងជួយអន្តរាគមន៍បញ្ចុះតម្លៃផ្គត់ផ្គង់អគ្គិសនីដល់វិស័យស្រូវអង្ករកម្ពុជា។

លោក **សុខ ពុទ្ធិវុធ** បានជម្រាបជូនរដ្ឋមន្ត្រីអំពីបេសកម្ម និងដំណើរការវិវត្តន៍ របស់សហព័ន្ធស្រូវអង្ករកម្ពុជា ក្នុងការជួយលើកស្ទួយដល់ការនាំអង្ករចេញ ដែលនឹងនាំមកនូវផលប្រយោជន៍ដល់សមាជិក ជាពិសេសនោះគឺបានដល់កសិករខ្មែរ។ លោកប្រធានសហព័ន្ធក៏បានជម្រាបប្រាប់អំពីផលលំបាកមួយចំនួនទាក់ទងនឹងបញ្ហាថ្លៃដើមខ្ពស់នៅក្នុងវិស័យស្រូវអង្ករ ដែលជាហេតុធ្វើឲ្យជួបការលំបាកក្នុងការប្រកួតប្រជែងជាមួយប្រទេសជិតខាង។

នៅក្នុងជំនួបនោះដែរ ឯកឧត្តមរដ្ឋមន្ត្រី **ស៊ុយ សែម** បានលើកឡើងអំពីកិច្ចខិតខំប្រឹងប្រែងរបស់ក្រសួងក្នុងការបញ្ចុះតម្លៃអគ្គិសនីជូនដល់វិស័យឯកជន និងប្រជាពលរដ្ឋ។
ដោយឆ្លើយតបទៅនឹងសំណើរបស់ ស.អ.ក ក្នុងការបញ្ចុះតម្លៃផ្គត់-ផ្គង់អគ្គិសនីដល់វិស័យស្រូវអង្ករកម្ពុជា ឯកឧត្តមរដ្ឋមន្ត្រី បានមានប្រសាសន៍ ផ្តល់ជាអនុសាសន៍ថា រោងម៉ាស៊ីនកិនស្រូវ ឬរោងចក្រកែច្នៃស្រូវអង្ករ អាចតខ្សែផ្ទាល់ទៅអនុស្ថានីយ៍របស់អគ្គិសនីកម្ពុជា (EDC) ឬបណ្តាញណាដែលមានបណ្តាញ EDC រត់កាត់ដោយមិនចាំបាច់តពីសេវាករឯកជនទេ។ មួយវិញទៀត ក៏អាចគិតពិចារណាអំពីជម្រើសក្នុងការប្រើប្រាស់អគ្គិសនីក្នុងពេលយប់ជំនួសវិញ។

ជាចុងក្រោយភាគីសហព័ន្ធស្រូវអង្ករកម្ពុជានឹងយកប្រសាសន៍និងអនុសាសន៍របស់រដ្ឋមន្ត្រីទៅពិចារណា និងជូនដំណឹងដល់ សមា-ជិករបស់ខ្លួន ដើម្បីធ្វើការជាមួយអគ្គិសនីបន្តទៀត៕





## ជំនួបពិភាក្សាការងារជាមួយថ្នាក់ដឹកនាំក្រសួងសាធារណៈការនិងដឹកជញ្ជូន



*សកម្មភាពជំនួបពិភាក្សាជាមួយថ្នាក់ដឹកនាំក្រសួងសាធារណៈការ និងដឹកជញ្ជូន*

ថ្នាក់ដឹកនាំសហព័ន្ធស្រូវអង្ករកម្ពុជា ដឹកនាំដោយប្រធាន ស.អ.ក លោក **សុខ ពុទ្ធិវុធ** និង សមាជិកគណៈកម្មាធិការប្រតិបត្តិកែទម្រង់ថ្លៃដើម បានជួបសម្តែងការគួរសមជាមួយឯកឧត្តម **ត្រាំ អ៊ីវតឹក** រដ្ឋមន្ត្រីក្រសួងសាធារណៈការ និង ដឹកជញ្ជូន និងមន្ត្រីជាន់ខ្ពស់កំពង់ផែស្វយ័តទាំងពីរផងដែរ នៅព្រឹក ថ្ងៃទី ២៣ ខែមេសា ឆ្នាំ២០១៥។

គោលបំណងនៃជំនួបនេះ គឺស្នើសុំឲ្យក្រសួងជួយដោះស្រាយបញ្ហាប្រឈមមួយចំនួន ដែលកើតមាននៅក្នុងវិស័យស្រូវអង្ករជាពិសេសពាក់ព័ន្ធនឹងការដឹកជញ្ជូនស្រូវអង្ករ។

លោក **សុខ ពុទ្ធិវុធ** បានជម្រាបជូនរដ្ឋមន្ត្រីនូវដំណើរការ និងបេសកម្មរបស់សហព័ន្ធស្រូវអង្ករកម្ពុជា ក្នុងការជួយលើកស្ទួយដល់ការនាំអង្ករចេញដែលនឹងនាំមកនូវផលប្រយោជន៍ដល់សមាជិកទាំងមូល ហើយជាពិសេសនោះគឺផលប្រយោជន៍នឹងបានដល់កសិករ។ នៅក្នុងឱកាសនោះដែរ លោកប្រធានសហព័ន្ធបានស្នើឯកឧត្តមរដ្ឋមន្ត្រី មេត្តាពិនិត្យលទ្ធភាពអន្តរាគមន៍លើមធ្យោបាយដឹកជញ្ជូន ដើម្បីធ្វើឲ្យការដឹកជញ្ជូនមានតម្លៃថោកនិងបង្កើនភាពប្រកួតប្រជែងជាងមុន។

នៅក្នុងជំនួបនោះដែរ ឯកឧត្តម រដ្ឋមន្ត្រីបានលើកឡើងពីផែនការអភិវឌ្ឍន៍លើមធ្យោបាយដឹកជញ្ជូន ទាំងផ្លូវគោក ផ្លូវដែក និង ផ្លូវទឹក ដើម្បីសម្រួលដល់ការដឹកជញ្ជូនទំនិញជាពិសេសកសិផល។

ជាចុងក្រោយ ភាគីសហព័ន្ធស្រូវអង្ករកម្ពុជា បានស្នើ ឯកឧត្តមរដ្ឋ-មន្ត្រី រៀបចំកិច្ចប្រជុំមួយដែលមានការចូលរួមពីតំណាងមកពីក្រុម-ហ៊ុនដឹកជញ្ជូន និងកំពង់ផែស្វយ័តទាំងពីរ ដើម្បីពិភាក្សាលើមធ្យោបាយ លើកដាក់ទំនិញនៅកម្ពុជាដែលមានតម្លៃចេះតែកើនឡើង ហើយគ្មានភាគីណាមួយទទួលខុសត្រូវ៕



## សហព័ន្ធស្រូវអង្ករកម្ពុជា ចូលរួមចំណែកយ៉ាងសំខាន់នៅក្នុងការធ្វើនំអន្សមយក្សរបស់ខ្មែរ ដែលបានជាប់ក្នុងកំណត់ត្រាពិភពលោក

សហព័ន្ធស្រូវអង្ករកម្ពុជាបានចូលរួម យ៉ាងសកម្មនៅក្នុងព្រឹត្តិការណ៍អង្គរសង្ក្រាន្តដែលសហការរៀបចំដោយ សហភាពសហព័ន្ធយុវជនកម្ពុជា (UYFC) និងក្រសួងពាណិជ្ជកម្ម (MOC)។ នៅក្នុងព្រឹត្តិការណ៍នេះ មានការធ្វើនំអន្សមយក្សទំងន់ ៤ តោនជាងដើម្បីបំបែកឯកត្តកម្មពិភពលោក (World Guiness Record)។ នំអន្សមនេះសហការផលិតដោយ UYFC, MOC, CRF និង សមាគមចុងភៅកម្ពុជា។

សហព័ន្ធស្រូវអង្ករកម្ពុជា បានចូលរួមឧបត្ថម្ភជាវត្ថុធាតុដើមសម្រាប់ធ្វើនំអន្សោមយក្សនេះ ដូចជាអង្ករដំណើប សាច់ជ្រូក និងស្លឹកចេកជាដើម។ បន្ថែមពីនេះ សហព័ន្ធស្រូវអង្ករកម្ពុជា ក៏មានការដាក់តាំងស្តង់អង្កររបស់សមាជិក ជូនដល់ប្រជាពលរដ្ឋដែលបានអញ្ជើញមកចូលរួមក្នុងព្រឹត្តិការណ៍អង្គរសង្ក្រាន្ត ឆ្នាំ ២០១៥ ក្នុងខេត្តសៀមរាបនេះផងដែរ។

ប្រភេទពូជអង្ករខ្មែរ និងពូជស្រូវប្រមាណជាង ១០ពូជ ត្រូវបានដាក់តាំងបង្ហាញ ក្នុងស្តង់ពិព័ររបស់ ស.អ.ក។ ទាំងបងប្អូនប្រជាពលរដ្ឋខ្មែរ និងភ្ញៀវអន្តរជាតិជាច្រើនចូលទស្សនាស្តង់ពិព័រណ៌ ស.អ.ក និងមានការចាប់អារម្មណ៍ចំពោះប្រភេទ និងពូជអង្ករខ្មែរ។ ក្រៅពីការទស្សនានូវការដាក់តាំងបង្ហាញប្រភេទពូជស្រូវ និងអង្ករ ពួកគាត់បានសួរនូវសំណួរពាក់ព័ន្ធជាច្រើនអំពីការផលិត ប្រភព គុណភាព និងទីផ្សារជាដើម។

យើងបានចែកជូនប្រជាពលរដ្ឋ និងថ្នាក់ដឹកនាំរដ្ឋាភិបាល នូវប៉ាន់គំរូប្រភេទពូជស្រូវ និងអង្ករមួយចំនួន ដើម្បីពួកគាត់បានសាកភ្លក្ស និងដាំបាយហូប។ ពួកគាត់មានការសប្បាយចិត្តជាខ្លាំង និងបានកោតសរសើរចំពោះក្រុមការងាររបស់សហព័ន្ធស្រូវអង្ករកម្ពុជា ដែលបានរៀបចំឲ្យមានស្តង់ពិព័ណនេះឡើង៕



ប្រភាពនៅខេត្តសៀមរាប











## កិច្ចប្រជុំពិភាក្សាក្រុមការងារវិស័យឯកជន និងរាជរដ្ឋាភិបាលរបស់វិស័យស្រូវអង្ករកម្ពុជា

នៅរសៀលថ្ងៃទី ២៦ ខែឧសភា ឆ្នាំ ២០១៥ សហព័ន្ធស្រូវអង្ករកម្ពុជា បានដឹកនាំសមាជិកក្រុមប្រឹក្សាភិបាល និងសមាជិកគណៈកម្មាធិការរបស់ខ្លួនចូលរួមនៅក្នុង កិច្ចប្រជុំពិភាក្សាក្រុមការងារវិស័យឯកជននិងរាជរដ្ឋាភិបាលរបស់វិស័យស្រូវអង្ករកម្ពុជាដែលដឹកនាំដោយ ឯកឧត្តម កិត្តិសេដ្ឋាបណ្ឌិត **គាត ឈន់** ឧបនាយករដ្ឋមន្ត្រីប្រចាំការ និងជាប្រធានគណៈកម្មាធិការអភិវឌ្ឍន៍វិស័យឯក-ជននិងមានការចូលរួមពីសហភាគីរាជរដ្ឋាភិបាលមួយចំនួន ដូចជា ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ ក្រសួងសាធាណៈការនិងដឹកជញ្ជូន និង ក្រសួងសាប័នមួយចំនួនទៀត រួមជាមួយនឹងសហដៃគូពីវស័យឯកជន សរុបប្រមាណជាង ៥០នាក់។



*ឯកឧត្តម កិត្តិសេដ្ឋាបណ្ឌិត **គាត ឈន់***

នៅក្នុងអំឡុងពេលនៃកិច្ចប្រជុំ លោក **សុខ ពុទ្ធិវុធ** ប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា និងតំណាងឲ្យវិស័យឯកជនរបស់វិស័យស្រូវអង្ករកម្ពុជា បានរាយការណ៍ជូនដល់អង្គប្រជុំអំពី (១) សាវតាររបស់ស.អ.ក (២) សកម្មភាពការងារ និងលទ្ធផលគោលដែលសម្រេចបានក្នុងរយៈពេលមួយឆ្នាំកន្លងមក (៣) បញ្ហាប្រឈម និង (៤) ទិសដៅ និងសំណូមពរសម្រាប់ដោះស្រាយបញ្ហាប្រឈមក្នុងរយៈពេលខ្លី មធ្យម និងវែង។

ជាការឆ្លើយតបឯកឧត្តម កិត្តិសេដ្ឋាបណ្ឌិត **គាត ឈន់** ដែលជាប្រធានអង្គប្រជុំមានប្រសាសន៍កោតសរសើរ ចំពោះរបាយការណ៍និងលទ្ធផលការងារដែលសអ.ក សម្រេចបាន និងបានឯកភាពលើរាល់បញ្ហាប្រឈមសំខាន់ៗក្នុងវិស័យកសិកម្ម ដែលលើកឡើងដោយ សអ.ក និងបានគាំទ្រនិងព្រមទទួលយកនូវរាល់សំណូមពរទាំងអស់របស់ សអក ដោយបានលើកយកមកជជែកនិងឆ្លើយតបម្តងមួយៗ។ ចំពោះចំណុចសេសសល់ ឯកឧត្តម កិត្តិសេដ្ឋាបណ្ឌិត **គាត ឈន់** បានសម្រេចឲ្យស្ថាប័នរាជរដ្ឋាភិបាលពាក់ព័ន្ធទាំងឡាយយកទៅអនុវត្តតែម្តង ដោយសហការជាមួយវិស័យឯកជនដែលមាន ស.អ.ក ជាតំណាង៕



## កិច្ចប្រជុំរវាងក្រុមការងារ ស.អ.ក ជាមួយបណ្ដាក្រុមហ៊ុន shipping line និងកំពង់ផែទាំងពីរ

នៅរសៀលថ្ងៃទី ០២ ខែមិថុនា ឆ្នាំ ២០១៥ គណៈកម្មាធិការកែទម្រង់ថ្លៃដើមរបស់ស.អ.ក ដែលមានលោកឧកញ៉ា **គីម សាវុធ** ជាប្រធាន បានដឹកនាំក្រុមការងារដែលជាសមាជិករបស់ ខ្លួនចូលរួមកិច្ចប្រជុំមួយជាមួយបណ្ដាក្រុមហ៊ុន shipping line និងកំពង់ផែទាំងពីរនៅទីស្ដីការក្រសួងសាធារណៈការនិងដឹកជញ្ជូនក្រុងភ្នំពេញ។ កិច្ចប្រជុំនេះដឹកនាំដោយរដ្ឋមន្ត្រីក្រសួងសាធារណៈការនិងដឹកជញ្ជូន ឯកឧត្តម **ត្រាំ អ៊ីវតឹក** នឹងដែលមានអ្នកចូល រួមសរុបចំនួន ៣៩នាក់។


*រូបភាពនៅទីស្ដីការក្រសួងសាធារណៈការនិងដឹកជញ្ជូន*

គោលបំណងសំខាន់នៃកិច្ចប្រជុំគឺ ដើម្បីជជែកស្វែងរកដំណោះស្រាយឲ្យមានការបញ្ចុះថ្លៃដើមមួយចំនួនពាក់ព័ន្ធនឹងសេវាកម្មក្នុងការនាំចេញអង្ករកម្ពុជា។

នៅក្នុងអំឡុងពេលនៃកិច្ចប្រជុំ ប្រធានក្រុមការងារពីខាងស.អ.ក ឧកញ៉ា **គីម សាវុធ** បានជម្រាបជូនអង្គប្រជុំ នូវគំនិតសំខាន់ៗ ដែលបានស្នើឡើងដោយសមាជិក ស.អ.ក សុំឲ្យមានការបញ្ចុះថ្លៃ និងដំណោះស្រាយដែលក្នុងនោះរួមមាន៖ (១) សុំឲ្យថ្លៃ LOLO នៅកំពង់ផែភ្នំពេញ ចុះដូចកំពង់ផែកំពង់សោម គឺត្រឹម ២៤.៤០ ដុល្លារអាមេរិក (២) ស្នើសុំចុះ ២០% សម្រាប់តែអង្ករចំពោះថ្លៃ THC និង(៣) សុំឲ្យមាន Scanner នៅចុងទីនៃផ្លូវរថភ្លើង។

ប្រធានអង្គប្រជុំ ឯកឧត្តម **ត្រាំ អ៊ីវតឹក** បានសម្របសម្រួលកិច្ចប្រជុំដោយបើកការពិភាក្សា ហើយតំណាងក្រុមហ៊ុន shipping line និងកំពង់ផែស្វយតក្រុងភ្នំពេញ និងក្រុងព្រះសីហនុ បានឡើងបកស្រាយពន្យល់ លំអិតអំពីខ្ទង់តម្លៃនីមួយៗ និងមូលហេតុដែលនាំឲ្យមានការឡើងថ្លៃជាដើម ដោយមានការចោទសួរបន្ថែម ពីអ្នកចូលរួមមួយចំនួនផងដែរ។

ជាលទ្ធផល សមាជិកអង្គប្រជុំទាំងអស់បានស្វែងយល់កាន់តែច្បាស់អំពីបញ្ហាលំបាកទាក់ទងនឹងថ្លៃដើមខ្ពស់ នៃការនាំចេញអង្ករកម្ពុជា និងបានប្ដេជ្ញាយកទៅពិភាក្សានិងជជែកលំអិតបន្ថែមទៀតចំពោះរាល់សំណើទាំងបីចំណុចខាងលើ របស់ស.អ.ក ពិសេសថ្លៃ THC និង LOLO ដើម្បីឈានសម្រេចឲ្យមានការកាត់បន្ថយថ្លៃដើមក្នុងការនាំចេញអង្ករ។

## ស.អ.ក ដឹកនាំក្រុមហ៊ុនចំនួន ១០ ចូលរួមបេសកកម្មទីផ្សារនៅក្រុង Guangzhou, Shenzhen និងទីក្រុង Hong Kong ប្រទេសចិន

ក្រោមការសម្របសម្រួលរបស់សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) សហព័ន្ធស្រូវអង្ករកម្ពុជា (ស.អ.ក) បានដឹកនាំក្រុមហ៊ុនចំនួន ១០ ដើម្បីចូលរួមបេសកកម្មទីផ្សារ នៅក្រុង Guangzhou, Shenzhen និងទីក្រុង Hong Kong ប្រទេសចិន ពីថ្ងៃទី ៧ ដល់ ១២ ខែ មិថុនា ឆ្នាំ ២០១៥។
ក្រុមអ្នកចូលរួមទាំងអស់គ្នាបានទៅទស្សនា ផ្សារទំនើប និងហាងបោះដុំមួយចំនួន ក៏ដូចជាជួបនឹងឈ្មួញនាំអង្ករខ្លះ ដើម្បីស្វែងយល់


*រូបថតអនុស្សាវរីយ៍នៅទីក្រុងហុងកុង*

ពីលទ្ធភាពទីផ្សារអង្ករក្នុងប្រទេសចិន។
បេសកកម្មទីផ្សារនេះបានធ្វើឲ្យក្រុមការងារបានស្វែងយល់ពី ឱកាសទីផ្សារ ក៏ដូចជាបញ្ហាដែលត្រូវប្រឈមផងដែរ។ ឱកាសទីផ្សារគឺថា អង្ករក្រអូប មានការគាំទ្រនៅក្នុងទីផ្សារប្រទេសចិន ដូច្នេះវាល្អសម្រាប់កម្ពុជា ដោយសារកម្ពុជា ជាអ្នកផលិតអង្ករក្រអូបមួយ ក្នុងចំណោមអ្នកផលិតអង្ករក្រអូបសំខាន់ពីរ។ ហេតុដូចនេះហើយ កម្ពុជាគួរតែធ្វើការផ្សព្វផ្សាយ ឲ្យខ្លាំងពីអង្ករក្រអូបរបស់ខ្លួនទៅដល់អតិថិជន ប្រទេសចិន។ ក្រុមទាំងមូលបានធ្វើការស្វែងយល់ជាលក្ខណៈទូទៅថា អង្ករក្រអូបគឺមានសក្ដានុពលនៅលើទីផ្សារប្រទេសចិន ប្រសិនជាអង្ករថ្មីដែលមានភាពភ្លឺរលោង។
ចំណែកឯ បញ្ហាក្នុងការនាំអង្ករក្រអូបទៅកាន់ទីផ្សារប្រទេសចិនរួមមាន ៖ (១) បរិមាណ និងគុណភាពមិនទាន់មានភាពដូចគ្នានឹងស្ថិតស្ថេរនៅឡើយ (២) ការដឹកជញ្ជូនថ្លៃ និងមានរយៈពេលយូរបើប្រៀបធៀបនឹង ប្រទេសថៃ និងវៀតណាម និង(៣) អតិថិជនមិនបានដឹងអំពីអង្ករកម្ពុជា ។

ទោះបីជាតម្លៃគឺជាបញ្ហាចំបងមួយក៏ដោយ ការធ្វើម៉ាកយីហោអង្ករកម្ពុជាដើម្បីឲ្យមានតំណែង និងឈ្មោះច្បាស់លាស់នៅក្នុងទីផ្សារគឺមានសារៈប្រយោជន៍ណាស់៕



## ជំនួបពិភាក្សាការងារជាមួយថ្នាក់ដឹកនាំកំពង់ផែស្វយ័តភ្នំពេញ



សកម្មភាពកំពុងពិភាក្សាជាមួយថ្នាក់ដឹកនាំកំពង់ផែស្វយ័តភ្នំពេញ

នៅរសៀលថ្ងៃទី ០៦ ខែមិថុនា ឆ្នាំ ២០១៥ ថ្នាក់ដឹកនាំសហព័ន្ធស្រូវអង្ករកម្ពុជា (ស.អ.ក) ដែលរួមមានប្រធាន អនុប្រធាន និងក្រុមការងារលេខាធិការដ្ឋាន បានជួបពិភាក្សាការងារជាមួយថ្នាក់ដឹកនាំកំពង់ផែស្វយ័តភ្នំពេញ ដែលដឹកនាំដោយឯកឧត្តម **ហ៊ី ធាវី**។
គោលបំណងសំខាន់នៃកិច្ចជំនួបគឺ ដើម្បីពិភាក្សា និងស្នើសុំឲ្យមានការសម្រួលដល់ការនាំចេញអង្ករកម្ពុជា ពិសេសការបញ្ចុះថ្លៃ LOLO និងការងារពាក់ព័ន្ធមួយចំនួនទៀត។ ជាលទ្ធផល ឯកឧត្តមប្រធានកំពង់ផែភ្នំពេញ ក៏បានផ្តល់ចម្លើយជាវិជ្ជមានផងដែរ ចំពោះការស្នើសុំអោយមានការបញ្ចុះតម្លៃ LOLO៕

---

## ជំនួបពិភាក្សាការងារជាមួយថ្នាក់ដឹកនាំកំពង់ផែស្វយ័តក្រុងព្រះសីហនុ



រូបភាពកំពង់ផែស្វយ័តក្រុងព្រះសីហនុ

នៅព្រឹកថ្ងៃទី ១៨ ខែមិថុនា ឆ្នាំ ២០១៥ វេលាម៉ោង ១០និង ៣០នាទីព្រឹក ថ្នាក់ដឹកនាំសហព័ន្ធស្រូវអង្ករកម្ពុជា (ស.អ.ក) ដែលរួមមានប្រធាន អនុប្រធាន និងក្រុមការងារលេខាធិការដ្ឋាន បានជួបពិភាក្សាការងារជាមួយថ្នាក់ដឹកនាំកំពង់ផែស្វយ័តក្រុងព្រះសីហនុ នៅក្រុងព្រះសីហនុ។ គោលបំណងសំខាន់នៃកិច្ចជំនួបគឺ ដើម្បីពិភាក្សាការងារលើតម្លៃសេវាកម្មលើការលើកដាក់ (LOLO) ស្រូវអង្ករកម្ពុជាសម្រាប់បម្រើឲ្យការនាំចេញ។ ជាលទ្ធផល ក្រោយកិច្ចពិភាក្សាគ្នារួចមក ឯកឧត្តមប្រធានអគ្គនាយកកំពង់ផែស្វយ័តក្រុងព្រះសីហនុ បានឯកភាពបញ្ចុះតម្លៃសេវាកម្មលើការលើកដាក់ (LOLO) ស្រូវអង្ករកម្ពុជាសម្រាប់នាំចេញឲ្យនៅត្រឹម ២៤.៤០ ដុល្លារអាមេរិកក្នុងមួយកុងតែន័រដែលមានចំណុះ ២០ហ្វីត ទោះបីជាកុងតែន័រទាំងនោះចូលមកតាមច្រកណាក៏ដោយ ដោយគិតចាប់ពីថ្ងៃទី ០១ ខែកក្កដា ឆ្នាំ ២០១៥ តទៅ។ សូមបញ្ជាក់ថា ការបញ្ចុះតម្លៃនេះ គឺខាងកំពង់ផែក្រុងព្រះសីហនុផ្តល់ជូនតែសមាជិករបស់សហព័ន្ធស្រូវអង្ករប៉ុណ្ណោះ។

---

## ប្រធាន ស.អ.ក បានទៅបំពេញទស្សនកិច្ចជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទៅសាធារណរដ្ឋប្រជាមានិតចិន

កាលពីថ្ងៃទី ៣០ ខែមិថុនា ដល់ ថ្ងៃទី ០៥ ខែកក្កដា ឆ្នាំ២០១៥ ឯកឧត្តម **វង្សី វិស្សុត** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានដឹកនាំគណៈប្រតិភូកម្ពុជា ដែលមានសមាសភាពចូលរួមពីតំណាងឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ធនាគារអភិវឌ្ឍន៍ជនបទ ក្រុមហ៊ុនហ្គ្រីនត្រេដ (ក្រសួងពាណិជ្ជកម្ម) និងប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា ឯកឧត្តម **សុខ ពុទ្ធិវុធ** បានទៅបំពេញទស្សនកិច្ចសិក្សានៅទីក្រុងសៀងហៃ និងទីក្រុងចុងឈីង នៃសាធារណរដ្ឋប្រជាមានិតចិន។

តាមរយៈការបំពេញទស្សនកិច្ចនេះបានបង្ហាញឲ្យឃើញថា រដ្ឋាភិបាលចិនផ្តល់ការគាំទ្រដល់គម្រោងជំរុញផលិតកម្មស្រូវ និងការនាំចេញអង្កររបស់រាជរដ្ឋាភិបាលកម្ពុជា ហើយក្រុមហ៊ុនរដ្ឋចិនបានបង្ហាញនូវសុឆន្ទៈ និងបានត្រៀមខ្លួនក្នុងការសហការ និងចូលរួមអនុវត្តគម្រោងជាមួយភាគីកម្ពុជា ព្រោះថា ក្រុមហ៊ុនសុទ្ធតែមានសមត្ថភាព និងបទពិសោធន៍គ្រប់គ្រាន់ក្នុងការអនុវត្តគម្រោង ជាពិសេសលើការងារសាងសង់ឃ្លាំងការគ្រប់គ្រង និងប្រតិបត្តិការ ព្រមទាំងអាចសម្របសម្រួលជាមួយរដ្ឋាភិបាលចិនដើម្បីឲ្យកម្ពុជាទទួលកូតានាំចូលអង្ករទៅប្រទេសចិន។ប៉ុន្តែក្រុមហ៊ុនទាំងនោះនៅមិនទាន់យល់អំពីគោលបំណងនិងទស្សនាទានគម្រោងរបស់យើងច្បាស់លាស់នៅឡើយ ហើយក៏មិនទាន់បានរៀបចំជាឯកសារទស្សនាទាន និងសិក្សាសមិទ្ធិលទ្ធភាពរបស់គម្រោងឲ្យបានស៊ីជម្រៅ និងលម្អិតទៅឡើយដែរ។ ដូច្នេះ ទស្សនកិច្ចសិក្សាលើកនេះបានជំរុញឲ្យភាគីចិនយល់អំពីគោលបំណង និងទស្សនៈរបស់កម្ពុជាកាន់តែច្បាស់ ដែលអាចនាំឲ្យមានការរៀបចំ និងការសិក្សាគម្រោងកាន់តែប្រសើរជាងមុន ឆ្ពោះទៅរកការអនុវត្តក្នុងពេលដ៏ខ្លីខាងមុខនេះ៕

## កិច្ចប្រជុំជាមួយអាជ្ញាធរអគ្គិសនីកម្ពុជា

នៅរសៀល ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ ២០១៥ គណៈកម្មាធិការកែទម្រង់ថ្លៃដើមរបស់ សហព័ន្ធស្រូវអង្ករ កម្ពុជា បានជួបពិភាក្សាការងារជាមួយអាជ្ញាធរអគ្គិសនីកម្ពុជា នៅការិយាល័យ អាជ្ញាធរអគ្គិសនីកម្ពុជា ភ្នំពេញ ។ កិច្ចប្រជុំនេះដឹកនាំដោយ លោកឧកញ៉ា **គឹម សាវុធ** អនុប្រធានសហព័ន្ធស្រូវអង្ករ និងជាប្រធានគណៈកម្មាធិការកែទម្រង់ថ្លៃដើមរបស់ ស.អ.ក។

មានអ្នកចូលរួមទាំងអស់ ១៧រូប ក្នុងនោះមាន ចំនួន ១១រូប មកពីសហព័ន្ធស្រូវអង្ករកម្ពុជា និង ៥រូប មកពីអជ្ញាធរអគ្គីកម្ពុជា។ កិច្ចប្រជុំត្រូវបានធ្វើឡើងក្នុងគោលបំណង ដើម្បីស្នើសុំអាជ្ញាធរអគ្គិសនី ឲ្យមានការអនុវត្ត ផែនការយុទ្ធសាស្ត្របន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនីនៅព្រះរាជាណាចក្រកម្ពុជា សម្រាប់ឆ្នាំ ២០១៥ ដល់ ឆ្នាំ ២០២០ ចាប់ពីខែកញ្ញា ឆ្នាំ ២០១៥ ឬចុងឆ្នាំ ២០១៥ សម្រាប់វិស័យស្រូវអង្ករ។

នៅក្នុងអំឡុងពេលកិច្ចប្រជុំ ខាងសហព័ន្ធស្រូវអង្ករកម្ពុជា បានស្នើដល់អជ្ញាធរអគ្គិសនីកម្ពុជាចំនួន ២ ចំនុចសំខាន់ៗ៖ (ទី១) សុំឲ្យអាជ្ញាធរអគ្គីសនីកម្ពុជា ដាក់បញ្ចូលរោងម៉ាស៊ីនកិនស្រូវ ក្នុងតារាងឧបត្ថម្ភធន (ទី២) សុំឲ្យអាជ្ញាធរអគ្គិសនីកម្ពុជា គិតតម្លៃ សម្រាប់រោងម៉ាស៊ីនកិនស្រូវ ដូចគិតឲ្យសេវាកម្មដែរ នៅតំបន់ណាដែលបណ្ដាញ EDC ទៅដល់ ឬ គិតតម្លៃត្រឹមតែ ៦១០ រៀល ក្នុងមួយគីឡូវ៉ាត់។

ជាលទ្ធផលខាងអជ្ញាធរអគ្គិសនីកម្ពុជា បានយល់ព្រមយកសំណើខាងលើទៅរាយការណ៍ជូនថ្នាក់លើ ដើម្បីធ្វើការពិចារណា និង សម្រេចចិត្ត៕



## ប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា បានចូលរួមក្នុងកិច្ចប្រជុំពិគ្រោះយោបល់ស្ដីពីការអភិវឌ្ឍអាទិភាពរបស់កម្ពុជា

នៅថ្ងៃទី១០ ខែ កក្កដា ឆ្នាំ ២០១៥ ប្រធាន សហព័ន្ធស្រូវអង្ករកម្ពុជា លោក **សុខ ពុទ្ធិវុធ** បានចូលរួមក្នុងកិច្ចប្រជុំ ពិគ្រោះយោបល់ស្ដីពី ការអភិវឌ្ឍអាទិភាពរបស់កម្ពុជា ជាមួយតំណាងវិស័យឯកជន នៅសណ្ឋាគារ ឡឺរ៉ូយ៉ាល់ ភ្នំពេញ ។

គោលបំណងនៃការពិគ្រោះយោបល់ គឺដើម្បីបង្កើតការយល់ដឹងរួមគ្នាពី បញ្ហាការអភិវឌ្ឍ ចំណុចសំខាន់បំផុតរបស់កម្ពុជា ដែលចាំបាច់ត្រូវធ្វើការដោះស្រាយក្នុងរយៈពេល ពីរ ទៅ បី ឆ្នាំខាងមុខនេះ ។

ក្នុងអំឡុងពេលកិច្ចប្រជុំ លោក **សុខ ពុទ្ធីវុធ** ជាអ្នកសម្របសម្រួលកិច្ចប្រជុំ លើវិស័យកសិកម្ម។ ចំណុចសំខាន់ដែលបានពិ-ភាក្សាក្នុងកិច្ចប្រជុំនេះ រួមមានទាំង ផលិតកម្ម(ការបណ្ដុះបណ្ដាលការលើកទឹកចិត្តដល់ កសិករ និងការចាប់យកទីផ្សារ) ដំណើរការកែច្នៃ (ការស្រាវជ្រាវ និង ការអភិវឌ្ឍផលិតផលទីផ្សារ, និងលើកកម្ពស់ហេដ្ឋារចនាសម្ព័ន្ធ ទាំង ធារាសាស្ត្រ និងអគ្គិសនី) ការទទួលបាននូវហិរញ្ញវត្ថុ ដែលមានអត្រាការប្រាក់ទាប និង ភាពជាដៃគូរវាងវិស័យឯកជន និងរដ្ឋាភិបាល៕



# ពិធីចុះហត្ថលេខា លើអនុស្សរណៈនៃការយោគយល់គ្នា រវាងក្រសួងពាណិជ្ជកម្ម និងសហព័ន្ធស្រូវអង្ករកម្ពុជា




*ឯកឧត្តម **ស៊ុន ចាន់ថុល** និង ប្រធាន ស.អ.ក លោក **សុខ ពុទ្ធិវុធ***

នៅរសៀល ថ្ងៃទី ២៣ ខែកក្កដា ឆ្នាំ២០១៥ នៅសាលប្រជុំក្រសួងពាណិជ្ជកម្ម មានការរៀបចំពិធីចុះហត្ថលេខា លើអនុស្សរណៈនៃការយោគយល់គ្នា ស្តីពីការគាំទ្រហិរញ្ញវត្ថុ ដើម្បីពង្រឹងសមត្ថភាពសហព័ន្ធស្រូវអង្ករកម្ពុជា រវាងក្រសួងពាណិជ្ជកម្ម និងសហព័ន្ធស្រូវអង្ករកម្ពុជា។

ប្រធានសហព័ន្ធស្រូវកម្ពុជា លោក **សុខ ពុទ្ធិវុធ** បានមានប្រសាសន៍ថ្លែងអំណរគុណដល់ថ្នាក់ដឹកនាំក្រសួង ពាណិជ្ជកម្ម ពិសេសឯកឧត្តមទេសរដ្ឋមន្ត្រី **ស៊ុន ចាន់ថុល** ដែលបានគាំទ្រដល់ការងាររបស់សហព័ន្ធ និងបានរៀបចំឲ្យមានកម្មវិធីចុះហត្ថលេខាថ្ងៃនេះកើតមានឡើង។

ជាមួយគ្នានេះដែរ ឯកឧត្តមទេសរដ្ឋមន្ត្រី **ស៊ុន ចាន់ថុល** បានមានប្រសាសន៍សំណូមពរដល់ ស. អ. ក ឲ្យធ្វើការសហការគ្នាកាន់តែជិតស្និទ្ធថែមទៀតជាមួយក្រសួង ដោយអាចរៀបចំឲ្យមានកិច្ចប្រជុំរវាង ស.អ.ក ជាមួយក្រសួងរៀងរាល់ ៣ខែម្តង ហើយក្រសួងបានត្រៀមខ្លួន និងប្តេជ្ញាជាស្រេច ដើម្បីធ្វើការជាមួយ ស.អ.ក ឲ្យទទួលបានជោគជ័យសម្រាប់វិស័យស្រូវ អង្ករនៅពេលខាងមុខ។ ឯកឧត្តម មានប្រសាសន៍បញ្ជាក់ថា ជោគជ័យរបស់ ស. អ. ក គឺជាជោគជ័យរបស់រាជរដ្ឋាភិបាលកម្ពុជា និងជាជោគជ័យរបស់កសិករខ្មែរទាំងអស់គ្នាផងដែរ៕



## ជំនួបពិភាក្សាការងារជាមួយរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

នៅរសៀលថ្ងៃទី ២៨ ខែសីហា ឆ្នាំ ២០១៥៖ ថ្នាក់ដឹកនាំសហព័ន្ធស្រូវអង្ករកម្ពុជា ដឹកនាំដោយលោក **សុខ ពុទ្ធិវុធ** ប្រធាន ស.អ.ក និងឧកញ៉ា **គីម សាវុធ** អនុប្រធាន ស.អ.ក និងសមាជិកគណៈកម្មាធិការប្រតិបត្តិមួយចំនួន បានជួបសម្តែងការគួរសមជាមួយ ឯកឧត្តមបណ្ឌិតទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម។



*ឯកឧត្តម **ចម ប្រសិទ្ធ** និង ប្រធាន ស.អ.ក លោក **សុខ ពុទ្ធិវុធ** ពេលកំពុងពិភាក្សា*

គោលបំណងនៃជំនួប គឺដើម្បីសំដែងការគួរសម និងស្នើផ្តល់អនុសាសន៍ណែនាំអំពីគោលនយោបាយរបស់រដ្ឋាភិបាលក្នុងការគាំទ្រដល់ការនាំចេញវិស័យស្រូវ-អង្ករកម្ពុជា។

លោក **សុខ ពុទ្ធិវុធ** បានជម្រាបជូនរដ្ឋមន្ត្រីអំពីដំណើរការវិវត្តន៍របស់សហព័ន្ធស្រូវអង្ករកម្ពុជា ក្នុងការជួយលើកស្ទួយដល់ការនាំអង្ករចេញ និងគាំទ្រដល់សមាជិក ជាពិសេសកសិករខ្មែរ។ លោកប្រធានសហព័ន្ធក៏បានជម្រាបប្រាប់អំពីផលលំបាកមួយចំនួនទាក់ទងនឹងបញ្ហាថ្លៃដើមខ្ពស់នៅក្នុងវិស័យស្រូវអង្ករ និងបញ្ហាបរិមាណ និងគុណភាពស្រូវអង្កររបស់យើងនៅមានកម្រិត ដែលជាហេតុធ្វើឲ្យជួបការលំបាកក្នុងការប្រកួតប្រជែងជាមួយប្រទេសជិតខាង។

ជាកិច្ចឆ្លើយតប ឯកឧត្តមបណ្ឌិតទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** បានមានប្រសាសន៍កោតសរសើរ អំពីកិច្ចខិតខំប្រឹងប្រែងរបស់ថ្នាក់ដឹកនាំ ស.អ.ក និងអបអរសាទរចំពោះការវិវត្តន៍របស់ ស.អ.ក។

លើសពីនេះ ឯកឧត្តមបណ្ឌិតទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** បានផ្តល់នូវអនុសាសន៍មួយចំនួនជូន ស.អ.ក យកទៅពិចារណា និងយកចិត្តទុកដាក់បន្ថែមទៀត ដែលចំណុចទាំងនោះរួមមាន៖ (១)គួរពិនិត្យឡើងវិញឲ្យមានសុក្រិតភាព ចំពោះស្ថិតិនិទ្នន័យចំនួនស្រូវអង្ករប្រទេសយើងដែលមានពិតប្រាកដ (២) លទ្ធភាព និងវិសាលភាពនៃប្រព័ន្ធធារាសាស្ត្រសម្រាប់ការដាំដុះ (៣) សិក្សាអំពីសក្តានុពល និងជីជាតិដីនៅតំបន់នីមួយ បន្ទាប់មកអាចកំណត់តំបន់ (Zoning) សម្រាប់ការដាំដុះទៅតាមប្រភេទពូជ ផ្គត់ផ្គង់ទីផ្សារ (៤) គួរផលិតពូជណាដែលឆ្លើយតបទៅតាមទីផ្សារ (៥) គួរកំណត់លក្ខខណ្ឌឲ្យសមស្របមួយសម្រាប់កសិករក្នុងការអនុវត្ត Contract Farming (៦) យកចិត្តទុកដាក់លើការបាត់បង់ក្រោយការច្រូតកាត់ ឬប្រមូលផល ដោយងាកមកប្រើប្រាស់បច្ចេកវិទ្យាសមស្របណាមួយ (៧) ការប្រើភ្លើង ដោយច្នៃចេញពីអង្កាម (៨) ចំណាយលើការដឹកជញ្ជូនដោយគួរជម្រុញឲ្យមាន ផ្លូវរថភ្លើងពីខេត្តបន្ទាយមានជ័យទៅកំពង់សោម (៩) យន្តការក្នុងការប្រមូលទិញស្រូវពីកសិករ ដោយសហការជាមួយម៉ាស៊ីនតូចៗតាមមូលដ្ឋាន (១០) គួរជម្រុញបន្ថែមទៀតចំ-ពោះអង្ករចំហុយ និង(១១) គួរគិតគូរលើការច្នៃ និងនាំចេញផលិតផលផ្សេងៗទៀត ដែលច្នៃចេញពីអង្ករ។

ជាចុងក្រោយ ភាគីសហព័ន្ធស្រូវអង្ករកម្ពុជា បានអរគុណចំពោះថ្នាក់ដឹកនាំក្រសួង ដែលបានគាំទ្រ និងបន្តកិច្ចសហការជាមួយសហព័ន្ធស្រូវអង្ករកម្ពុជាទៅថ្ងៃខាងមុខ៕



## ជំនួបពិភាក្សាការងារជាមួយថ្នាក់ដឹកនាំអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា

នៅព្រឹកថ្ងៃទី ២០ ខែសីហា ឆ្នាំ២០១៥ ក្រុមការងារសហព័ន្ធស្រូវអង្ករកម្ពុជា ដែលដឹកនាំដោយប្រធានសហព័ន្ធ លោក **សុខ ពុទ្ធិវុធ** បានអញ្ជើញចូលរួមនៅក្នុងកិច្ចប្រជុំពិភាក្សាការងារមួយជាមួយថ្នាក់ដឹកនាំអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា នៅសាលប្រជុំនៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ក្រុងភ្នំពេញ។ សមាជិកស.អ.ក ចំនួន ១២ នាក់ និងថ្នាក់ដឹកនាំខាងគយចំនួន ១១នាក់ បានចូលរួមនៅក្នុងកិច្ចប្រជុំនេះ ដែលភាគីអគ្គនាយកដ្ឋានគយដឹកនាំដោយ ឯកឧត្តម **គុណ ញឹម** អគ្គនាយក នៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា។

គោលបំណងសំខាន់នៃកិច្ចប្រជុំគឺ ដើម្បីជម្រាបបង្ហាញជូន អំពី



បច្ចុប្បន្នភាពនៃវិស័យស្រូវអង្ករកម្ពុជា ជូនដល់អគ្គនាយកដ្ឋានគយ និងស្នើសុំកិច្ចសហការពីអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ក្នុងការលើកកម្ពស់ការប្រកួតប្រជែង និងកាត់បន្ថយថ្លៃដើមនៅក្នុងវិស័យស្រូវអង្ករកម្ពុជា។ នៅក្នុងអំឡុងពេលនៃកិច្ចប្រជុំ ប្រធាន

*តទៅទំព័រទី ១៥*

*តមកពីទំព័រទី ១៤*

សហព័ន្ធស្រូវកម្ពុជា បានលើកឡើងអំពីសំណើចំនួន ៣ ចំណុច របស់សហព័ន្ធដែលរួមមាន៖ ទី១ ៖ ស្នើសុំឲ្យមានការលើកលែងនូវការស្កេន (Scan) កុងតែន័រ នៅចុងទីនៃផ្លូវរថភ្លើង សម្រាប់តែអង្ករ ដើម្បីកាត់បន្ថយនូវពេលវេលា និងសោហ៊ុយ ។ ទី២៖ សុំឲ្យជួយរឹតបន្តឹងការយកពន្ធ ( អនុវត្តការបង់ពន្ធឲ្យបានត្រឹមត្រូវ និងគ្រប់ចំនួន) ចំពោះរាល់ការនាំអង្ករចូលពីប្រទេសជិតខាង និង ទី៣ ៖ ស្នើសុំកិច្ចសហការក្នុងការគ្រប់គ្រងទិន្នន័យនៃការហូរស្រូវចេញទៅប្រទេសជិតខាង។

ជាការឆ្លើយតប ឯកឧត្តម **គុណ ញឹម** អគ្គនាយក នៃអគ្គនាយក



ដ្ឋានគយ និងរដ្ឋាករកម្ពុជា បានស្វាគមន៍ និងទទួលយកនូវរាល់សំណើរបស់សហព័ន្ធ និងបានបកស្រាយឆ្លើយតបលើរាល់សំណើដូចខាងក្រោម៖ ទី១៖ ចំពោះសំណើសុំឲ្យមានការលើកលែងនូវការស្កេន (Scan) កុងតែន័រអង្ករ គឺខាងសហព័ន្ធគួរលើកសំណើនេះទៅកាន់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុផ្ទាល់។ ទី២ ៖ ចំពោះការអនុវត្តការយកពន្ធលើ រាល់ការនាំអង្ករចូលពីប្រទេសជិតខាង ខាងអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា បានទទួលការណែនាំពីឯកឧត្តមរដ្ឋមន្ត្រី ហើយយើងបានចាត់ចែងណែនាំទៅដល់មន្ត្រីរបស់យើងនៅតាមគ្រប់មាត់ច្រកទាំងអស់រួចហើយ ( ជាពិសេសនៅច្រកបន្ទាយចក្រី និងច្រកភ្នំឌិន) ដែលការយកពន្ធគឺប្រមាណ ២១ដុល្លារអាមេរិកក្នុងមួយតោន។

សម្រាប់កិច្ចសហការគ្នាទៅថ្ងៃខាងមុខ ភាគីអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា សូមចាត់លោកអគ្គនាយករងម្នាក់ ជាអ្នកទទួលរាល់ព័ត៌មាន និងកិច្ចសហការជាមួយខាងភាគីសហព័ន្ធស្រូវអង្ករកម្ពុជា៕



## សហព័ន្ធស្រូវអង្ករកម្ពុជា ចូលរួមនៅក្នុងវេទិកាធុរកិច្ចកម្ពុជា-បេឡារូស

